# វគ្គ

## រឿងពីមុន

សម្រិបជើងមនុស្សនៅខាងក្រៅ....សូរទ្វារក៏លាន់បិទវិញគ្រឹប។

មានគេចូលមកហើយ អារម្មណ៍អរភើត....គិតថានឹងសសៀរខ្លួនទៅក្បែរទ្វារទាំងស្លៀកកន្សែងពោះគោត្រឹមមួយកំណាត់ក្រោមផ្ចិតបែបនេះ ទៅហាមាត់សុំជំនួយ ប៉ុន្តែ....

តាមរយៈប្រឡោះទ្វារដែលហើបប្រមាណជាមួយថ្នាំងម្រាម ខ្ញុំត្រូវភាំង.... មើលពីនេះទៅក្រៅ ខ្ញុំមិនដែលឃើញខ្ទង់មនុស្សប្រុសណាមានអានុភាព បែបសម្រស់ទាក់ទាញដល់ថ្នាក់នេះទេ។

ទាក់ទាញបែបម៉េច? គឺបែបដែលក្រឡេកទៅឃើញកាលណាភ្លាម សម្តីប្រុងថានិយាយភ្លេចអស់ខ្យុយទៅបាត់ដល់ណាមិនដឹង ហើយអាការៈត្រៀមរកជំនួយក៏រុះរោយកប់កន្ទើតអារម្មណ៍១០០ជំពូករេមកផ្តោតតែលើសាច់ដុំណែនណាន់របស់គេ។

ម្នាក់នេះក្រៅពីធ្វើឱ្យខ្ញុំភ្លេចថា ខ្លួនឯងកំពុងស្លៀកកន្សែង ហើយកំពុងបាត់ខោអាវឯកសណ្ឋានអស់រលីង ថែមទាំងបង្ខំឱ្យខ្ញុំភ្លេចគិតថា ខ្លួនឯងកំពុងតែធ្វើអ្វីនៅទីនេះទៀតផង។ ភ្លាមៗនោះ អ្វីដែលខ្ញុំសកម្មរកនឹក គឺសួរខ្លួនឯងថា គេម្នាក់នេះជាអ្នកណា?

ទោះយ៉ាងណា នឹកនៅតែមិនឃើញ គិតមិនចេញពីបុគ្គលភាពនៃរាងកាយខ្ពស់ស្រាវ ស្មាទាំងសងបើកធំទូលាយ ផ្ទត់សាច់គ្រប់កន្លែង មើលទៅពិតជាប្រភេទរាងកាយដែលបានលត់ដំស្ពំខ្លួនជាមួយការធ្វើកាយសម្ព័ន្ធខ្លាំង។

គេលើកអាវយឺតកីឡាមកពាក់ដោយបោះកំភួនដៃទាំងសងទៅលើ។ សកម្មភាពរហ័សនោះរហ័ស មាំនោះមាំ ទាំងព្រមដោយសែនទាក់ភ្នែក មន្តស្នេហ៍សណ្តំ ល្អប្រណីត ទាក់ចិត្តដក់ជាប់ដូចត្រូវអំពើ និយាយរួម attractive charming elegant engaging glamorous គឺមានទាំងអស់ទៅហើយ សូម្បីតែមើលពីក្រោយប៉ុណ្ណឹងសោះ ចុះទម្រាំ....

អាវPumaរបស់គេធ្លាក់មកសន្សឹមៗ ជាសញ្ញាឱ្យដំណឹងខ្ញុំផងដែរថា នេះជាឱកាសចុងក្រោយដែលខ្ញុំបានឃើញរាងកាយគេ។ ក៏ជាមូលហេតុធ្វើឱ្យខ្ញុំត្រូវបន្តឈរស្កុបទ្រឹងដោយសោកស្តាយ ចំហមាត់ ស្ងប់ស្ងៀមម្នាក់ឯងរវាងនិស្ស័យពីព្រេងមកបានឃើញមនុស្សពិសេស និង រវាងការសោកស្តាយទាំងមិនទាន់ឃ្លាតពីគេនៅឡើយផង។

MY Buddha សូម្បីតែពេលនេះទៀត គេឱនហើយ គឺឱនមកបើកសាក់កាដូរើរកអ្វីបន្ត....កុំថា រើខោមកផ្លាស់ទៀតណ៎ា you កំពុងសម្លាប់ Me!

ចិត្តមួយដាស់ខ្ញុំភ្លាមៗថា បើខ្ញុំនៅតែលបមើលគេតាមបែបនេះទៀត គេក៏នឹងឃើញខ្ញុំវិញមិនខាន។ ណាមួយខ្ញុំកំពុងតែ នៅក្នុងបញ្ហាផង មនុស្សប្រុសស្រែកឃ្លានណាមិនដឹងបានលួចយកអាវខ្ញុំទៅបាត់ពេលដែលខ្ញុំកំពុង តែងូតទឹក រៀបចំខ្លួន ក្រោយម៉ោងកីឡា។

ជិតដល់ម៉ោងចូលរៀនហើយ! គេធ្វើនេះមានន័យថាម៉េច ចង់ធ្វើបាបខ្ញុំច្បាស់ក្រឡែត។

មិនទាន់រកជំនួយបានផង ស្រាប់តែក្រឡេកទៅទៀត ត្រូវមុខស្ពឹកជាមួយនឹងរូបរាងទេវបុត្រដែលទម្លាក់ខោខូវប៊ិយដល់ត្រឹមជង្គង់។

ដឹងតែទៅរៀនយឺតហើយម្តាយ ប៉ុន្តែជ្រុលប៉ុណ្ណឹងហើយ យឺតក៏យឺតចុះ! បានមើលទិដ្ឋភាពដ៏ពុះកញ្ជ្រោលមួយនេះ បើទោះបីជាត្រូវ detention គ្រូពិន័យដកពិន្ទុ ឬក៏ឱ្យឈរអេះម៉េះក្រៅថ្នាក់ អត់បញ្ហាគឺ អត់បញ្ហាមែន ប៉ុន្តែបញ្ហាធំពេលនេះកើតឡើងហើយ គេដូចជា បង្អង់នូវសកម្មភាពរួសរាន់នោះចេញ ហើយក្រោកឡើងមកយឺតៗពីការឱនស្រាតខោមុននេះ។ ច្បាស់ណាស់គេឃើញខ្ញុំតាមកញ្ចក់ហើយ!

«ងាកមុខចេញ បិទទ្វារវិញJames!»

ខ្ញុំប្រាប់ខ្លួនឯងដោយមុខក្រហម ប៉ុន្តែធ្វើអីបាន? ខួរក្បាលបញ្ជាប៉ុណ្ណឹងហើយ កាយខ្ញុំ ដៃជើង ស្បែក មុខមាត់នៅតែស្ពឹកទាញមិនកម្រើក រហូតដល់គេបែរមុខខ្វាក សម្លឹងខ្ញុំចំៗ។

ក្រៅពីខ្នងដូចកំពូលកីឡាករ កំភួនដៃវែងមាំ សាច់រលោងស្រអែម កម្ពស់ស្រាវត្រង់ស្ដើងចង្កេះមាំ មុខដែលបែរមករឹតតែអង់អាចណាស់ Dashing!

លោកព្រះ! ម្ដេចលោកនេះមានអ្នកខ្លះ ត្រូវបានមេឃដីរចនាមកជាប្រុសល្អទាំងព្រមរកចន្លោះនឹងកាត់សេចក្តីឱ្យអន់ខ្លះគ្មាន?

«អ្នកណា? មកលឺបលអីនៅហ្នឹង»

សំណួរនេះគេបញ្ចេញមកតាមភ្នែក មិនមែនមាត់ទេ។ នេត្រាគេទាំងសង បានដាក់ចេញនូវសំណួរខ្លីសមតតខ្មោះជាមួយកិរិយាហំហាននេះ គឺភ្នែកបាននិយាយ ជំនួសឱ្យមាត់របស់គេដែលនៅស្ងៀមៗរក្សាចរិតអំណាចនៃសម្រស់ដ៏កម្រ។

មួយប៉ព្រិចភ្នែកដែលខ្ញុំភាំងៗ គេដៀងរហ័សណាស់សម្លឹងដើមទ្រូងខ្ញុំ ដែលទទេស្អាតគ្មានអាវ ក្បាលពោះរបស់ខ្ញុំបន្ទាប់មកកន្សែងលើចង្កេះរបស់ខ្ញុំ។

«ខ្ញុំបាត់ខោអាវឱ្យបង! ខ្ញុំបាត់ឯកសណ្ឋាន! ទុកនៅហ្នឹងមិញសោះ!»

គេដូចជាយល់ការណ៍លឿន។ ជាមួយនឹងអាកប្បកិរិយាស្ងប់ស្ងាត់នឹងនរ សម្រស់របស់គេកាន់តែមុតស្រួចបុកចូលជ្រៅ មួយគន្លាក់ហើយមួយគន្លាក់ទៀត ក្នុងបេះដូងក្មេងប្រុសបរិសុទ្ធដូចជាខ្ញុំ។

គេមិនទាន់និយាយអ្វីនៅឡើយ មួយម៉ាត់ណាក៏គ្មាន ចាប់ពីយើងបានជួបគ្នា ប៉ុន្តែការសម្លឹងនិងភាពស្ងប់ស្ងាត់របស់គេ បាននិយាយនូវភាសារាប់ពាន់ម៉ាត់ជាសម្ងាត់សម្រាប់ខ្ញុំក្នុងឆាកជួបគ្នាជាលើកដំបូងបង្អស់នេះ។

«ខ្ញុំមិនដឹងបានអីស្លៀកទេ! គេចូលរៀនអស់ហើយ!»

ខ្ញុំវាចាខ្សាវៗបន្ថែមនៅខណៈទឹកមុខគេប្តូរសន្សឹមៗ។

មុននេះពេលដែលងើបមុខមកពីកញ្ចក់ ឃើញពិតណាស់ថាគេមានក្រសែភ្នែកមិនពេញចិត្តវត្តមានលឹបលរបស់ខ្ញុំ ក៏មាត់គេមិនគន្លាស់ ប៉ុន្តែឥឡូវនេះទៀត ទោះគេខ្សែភ្នែកគេហាក់ដូរមកជាយល់ចិត្ត ក៏គេនៅតែមិនហារលាស់អណ្តាតនិយាយអ្វីបន្តិចណាដដែល។

ទោះជាប្រុសសម្តីមាស តែដែលខ្ញុំបានឱកាសនៅទីនេះ មានតែខ្ញុំនិងគេ វាល្អពេកហើយ។

បេះដូងខ្ញុំបញ្ជាភ្លាមៗឱ្យមាត់និយាយតម្អូញបន្ថែមដោយយកដៃ កាន់លើកន្សែងពោះគោផង៖

«ពួកហ្នឹងឧស្សាហ៍លេងរបៀបហ្នឹងណាស់បង! ចង់ឱ្យគ្រូពិន័យដកពិន្ទុខ្ញុំ!»

គេធ្លាក់សេចក្តីអាណិតតាមរយៈកែវភ្នែក ដែលសម្លឹងមកខ្ញុំស្រទន់។ មាត់គេជ្រិតនៅស្មើរៗស្មើៗដដែលតែក៏ហាក់បង្កប់ស្នាមញញឹមតិចតួច។ ទោះណាជាគេនៅតែមិនមាត់ ប៉ុន្តែឃើញឱនទាញខោស សម្រាតបង្ហើយធ្វើហី។

មើលពីនេះទៅ គេតែបន្តមានទឹកមុខជាមនុស្សឌឺណាស់ គឺដោយស្ងប់ស្ងៀម តែពិតជាឌឺ ១០០។ ទោះមាត់មិននិយាយតបត តែគេមានអំនួតម្យ៉ាង អាថ៌កំបាំង ដែលគេដឹងខ្លួនថា បានយកប្រៀបលើបេះដូងក្មេងប្រុសដូចខ្ញុំទៅហើយ នៅតែប្តូរសម្លៀកបំពាក់ឃឹតៗ។

ខ្ញុំមិនហ៊ានសម្លឹងគេទៀតទេ ទោះបេះដូងលោតត្រូវការយ៉ាងណា ខ្ញុំនៅតែបែរទៅម្ខាង គេចភ្នែកចេញ។

តើគេធ្វើនេះ មកពីមានចរិតអំនួតនឹងរូបរាងគេ ឬមកពីគេយល់ថាប្រុសដូចគ្នា?

ពីចំហៀងកន្ទុយភ្នែកខ្ញុំឃើញគេធ្វើសកម្មភាពស្លៀកខោកីឡាឡើងវិញ ហើយងើបមុខសម្លឹងខ្ញុំផងដែរ។ ចុងក្រោយខ្ញុំឮសូរស្នូរទាញរូត....

គឺគេទាញសាក់កាដូគេ បើកយកអ្វីមួយចេញមក។

«កុំប្រាប់ថា ឱ្យខោអាវមកខ្ញុំពាក់ណ៎ា! តែបើថាបំណាច់នឹងតាំងចិត្តឱ្យហើយ ឱ្យខោអាវណាដែលទើបពាក់ហើយមិញថ្មីៗមកក៏បាន ខ្ញុំចង់ដឹងក្លិនប្រុសស្អាតថាម៉េចវិញ?!»

ខ្ញុំគិតអ៊ីចឹងមែន តែក៏អត់និយាយចេញមកទេ ទោះម៉េចងព្យួរជើងឡើងលើ ក៏ខ្ញុំមិនហ៊ានរបូតសម្ដីអាថ៌កំបាំងដែលកំពុងលួចគិតនេះចេញមកក្រៅដែរ។

ប្រហែលជាការគិតបែបរំភើបៗបានញ៉ាំងឱ្យបបូរមាត់ខ្ញុំញញឹមដោយមិនដឹងខ្លួនហើយ បានជាពេលគេបែរមក ខ្ញុំរកតែទម្លាក់ស្នាមញញឹមនោះវិញក៏មិនទាន់។

ស្រេច! គេមើលដឹងសេចក្ដីរាយមាយនៅក្នុងបេះដូងរបស់ខ្ញុំបាត់ហើយដឹង?

ទោះដឹងថាមិនសម តែជ្រុលពេលទៅហើយ គេងាកមកវិញចំពេលខ្ញុំនៅឈរភាំងញញឹមដូចឆ្កួត!

ដូចខ្ញុំគិតមែន គេនេះមើលដឹងចិត្តយើងណាស់! មើលដឹងពីអាថ៌កំបាំងនៃបេះដូងទន់ខ្សោយរបស់ក្មេងប្រុសម្នាក់នេះ វិភាគឡើងយល់អស់ទៅហើយ បានជាបបូរមាត់របស់គេឥឡូវនេះ អមលម្អមកជាមួយស្នាមឌឺៗ។

ក្រសែភ្នែកគេដែលសម្លឹងមកខ្ញុំ ហាក់ដូចជាបង្កប់ន័យអ្វីពិបាកពន្យល់ ហើយគេក៏លែងទៅសម្លឹងកន្លែងណាទាំងអស់ គឺបុកមុតជ្រៅៗដល់ក្នុងប្រស្រីភ្នែកខ្ញុំតែម្ដង។

«ពាក់ខោអាវបងសិនទៅ!»

អូយ!!!!

តែប្រាំមួយម៉ាត់នេះពិតមែន ប៉ុន្តែខ្ញុំយកពាក្យនេះទៅទន្ទេញរាប់ពាន់ដងរហូតដល់ចាំវាក្នុងបេះដូងមិនថាយប់ឬថ្ងៃ ទៅដល់ណានៅកន្លែងណា។

«អូខេទទួលជានិច្ច! ដោយសប្បាយចិត្ត!»

នេះហើយការជួបគ្នាដំបូងរវាងខ្ញុំនិងបងទេពណារ៉ា។

ស្នេហាដំបូង តែងតែគិតទៅដល់ការរស់នៅក្បែរគ្នា អស់មួយជីវិត។

គ្រប់គ្នារិះគន់ថា មានស្នេហានៅវ័យ១៦ឆ្នាំ គឺក្មេងពេកហើយ តែពួកគេមិនស្គាល់ស្នេហាផងមិនដឹង? ស្នេហាជារឿងបេះដូងមនុស្សណា៎ា វាមិនបានបង្កើតឡើងមកដោយចេតនា ឬព្រៀងទុកមកឯណា ខ្ញុំបញ្ជាវាមិនបានផង ម៉េចអ្នកក្រៅម្នាក់ៗចេះតែចង់មកបញ្ជាបេះដូងខ្ញុំ?

តែគ្រប់យ៉ាង ពិតជាមានតម្លៃណាស់ពេលដំបូងៗដែលគេបានបង្ហាញខ្លួន។ សម្រាប់ខ្ញុំស្នាមញញឹមរបស់គេ បានផ្លាស់ប្តូរជីវិតរបស់ខ្ញុំ។

ពន្លឺភ្នែករបស់គេមានអានុភាពផ្លាស់ខ្ញុំពីរបៀបជាមនុស្សគល់ឈើ ក្លាយមកជាស្វាហាប់មានកម្តៅ និងរវាសរវៃ។

ក្រោយមកខ្ញុំដឹងថា គាត់បង្ហាញខ្លួននៅសាលានេះ ក្នុងនាមជាសិស្សច្បង ដែលធ្លាប់រៀននៅទីនេះជំនាន់ជាង៧ឆ្នាំមុន។ តាមពិតគាត់ឈ្មោះ ទេព ណារ៉ា តែខ្ញុំចូលចិត្តហៅគាត់ថា បង TN ថែមទាំងSaveឈ្មោះគាត់កាត់ៗបែបនេះក្នុងទូរសព្ទ ទុកជាការសម្ងាត់ដ៏ផ្អែមល្ហែមមួយរបស់ខ្ញុំខ្លួនឯង។

ថ្ងៃដែលខ្ញុំជួបគាត់ក្នុងបន្ទប់ផ្លាស់ខោអាវ គឺពេលដែលគាត់មករៀបខ្លួនទៅបង្រៀនបាល់បោះក្រុមជម្រើសរបស់សាលាត្រៀមចេញទៅសិង្ហបុរីប្រកួត។

គ្រប់យ៉ាងថៃដន់សុទ្ធសាធបើនិយាយតាមធម្មតា ប៉ុន្តែបើនិយាយតាមបេះដូងនេះជាកម្រងនិស្ស័យមួយ។

ក្រៅពីបានខោអាវគាត់យកទៅដេកឱបហើយ ស្អែកឡើងខ្ញុំជិះកង់មកសាលា ព្រោះថាចេញពីនោះគ្នាខ្ញុំ៤នាក់ មានកម្មវិធីជិះកង់មួយទៅអរិយក្សត្រវិលជុំ អ៊ីចឹងខ្ញុំមិនបានឱ្យម៉ាក់ជូនមកដូចរាល់ដងទេ។

ពេលហៀបនឹងចតកង់ចោល ស្រាប់តែខ្ញុំឃើញខ្នងគាត់ពីក្រោយ។ តាមពិតខ្ញុំអត់ចូលចិត្តមើលគេពីក្រោយទេ អ្នកណាក៏ដោយ ប៉ុន្តែមិនដឹងជានិស្ស័យអី មួយក្រឡេកកម្មនេះ ខ្ញុំឃើញកាយសម្បទាណែនហាប់របស់គាត់ដែលកំពុងធ្វើសកម្មភាព បង្ហាញពីរបៀបហាត់ប្រាណដល់ក្រុមកីឡាបាល់បោះនៅក្នុងសាលាយើង។

មិនដែលដឹងសោះថា សាលាយើងមានអតីតសិស្សជាជើងឯកខាងបាល់បោះ តាំងពីខ្ញុំនៅក្មេងបៀមដៃ ធ្លាប់ចេញទៅប្រកួតនៅសិង្ហបុរីហើយបានមេដាយត្រឡប់មកវិញ។ ខោអាវគាត់មិនទាន់បោកស្ងួត អ៊ីចឹងខ្ញុំអត់មានលេសឯណានឹងចូលទៅរកគាត់នៅឡើយប៉ុន្តែ សេចក្តីសង្ឃឹមជាច្រើនបានកើតមានឡើងមកលើជីវិតក្រៀមក្រោះរបស់ខ្ញុំ។

ដោយសារខ្ញុំតាមមើលគាត់មិនដាក់ភ្នែករហូតដល់ដើរទៅបុកគ្រូគណិត ដល់អ៊ីចឹងគេក៏ល្បីភ្លាមៗថា ខ្ញុំលង់ប្រុសស្អាតជាសិស្សច្បង។

អត់ខ្វល់!

ពេលដដែលនោះ ខ្ញុំបានទទួលព័ត៌មានជាច្រើនជុំវិញបងTN ដោយការរុករកតាមវិធីសាស្រ្តលាក់ការណ៍រាប់រយប្រភេទ ដែលមនុស្សវ័យជំទង់ដូចខ្ញុំចេះថ្មីក។

មិននឹកស្មានថា ពេលខ្ញុំបានទទួលព័ត៌មានពីគាត់ គាត់ក៏បានទទួលព័ត៌មានពីខ្ញុំដែរ។ ខ្ញុំជាក្មេងប្រុសម្នាក់ស្គមខ្ពស់ មានរោគចិត្តតិចៗព្រោះបញ្ហាក្នុងគ្រួសារដែលធ្វើឱ្យតាំងពី១០ឆ្នាំមកម្ល៉េះ ខ្ញុំក្លាយជាអត់ចង់និយាយ អត់ចង់ស្តី។

រៀននៅសាលាអត់មានមិត្តនឹងគេ មិនចាប់អារម្មណ៍គ្រប់យ៉ាង ត្រមុតត្រមុយ ខ្លាចគ្រូ មុខគាត់មិនដែលហ៊ានមើល ឃើញគាត់តែពីចម្ងាយក៏រត់ប្រែនបាត់ តែនៅសុខៗ មានព័ត៌មានហ៊ានដើរបុកគ្រូដោយសារតែជក់ភ្នែកតាមមើលសាច់ដុំសាច់ដុំសិស្សច្បង?

ជាការពិត អាចពណ៌នាថា ជាសេចក្តីរំភើប នៅពេលដំបូងមួយ ដែលយើងកំពុងគិតពីអ្នកណាម្នាក់ហាក់ដូចជាបង្ហាញខ្លួនមក ក៏ក្លាយមនុស្សពិសេសភ្លាមៗឡើងក្នុងជីវិតយើងបាន។

ការងារស្រាវជ្រាវរកព័ត៌មានគេនៅក្នុងបណ្តាញសង្គម ហើយព្យាយាមសួរនាំអ្នកនេះអ្នកនោះអំពីគេថែមទាំងសង្ឃឹមថា អាចយកកង់មកសាលាម្តងទៀត ធ្វើជាទៅចតនៅកន្លែងហ្នឹងដដែល បានលេសឃើញគេ។

«យកកង់ទៅសាលាទៀតហើយកូន?!»

«បាទម៉ាក់ ហាត់ប្រាណ!»

«បែកញើសប្រឡាក់អត់កូន?!»

«មានអីឯណាម៉ាក់?!»

«ចុះព្រែងថ្ងៃមុនថា ខ្លាចធុំក្លិនខ្លួនដល់គ្រូ?!»

«អត់មានផង!»

«ជិះមើលមុខក្រោយណ៎ាកូន!»

«បាទ!»

ជាលើកដំបូងក្នុងរយៈពេល៥ឆ្នាំ ដែលគាត់សួរ១០ម៉ាត់ បានខ្ញុំឆ្លើយតបទាំង១០ដង។ ពីមុនសួរ៥ដងឆ្លើយមួយម៉ាត់ ឬអាចមិនមានចម្លើយ។

មនុស្សមានអារម្មណ៍ល្អ អ្វីក៏ល្អដែរ។

នេះជាថ្ងៃទីបីហើយដែលធ្វើជាដាក់កង់ ហើយងើបមុខមកលួចមើលសិស្សច្បងទៀត គេហាក់ដឹងខ្លួន ហើយងាកមុខមកញញឹមដាក់ខ្ញុំ។

មិងមាំង!

ធ្វើអីបាន?

បេះដូងកំពុងត្រូវសរព្រះរាម!

ស្នាមញញឹមគេនិងកែវភ្នែកស្រឹមស្រទន់ជ្រាលជ្រៅទាំងគូដែលបានសម្លឹងមក ហាក់បង្ហាញអត្ថន័យស្រេចថា គេដឹងគ្រប់យ៉ាង គ្រប់ចលនា គ្រប់ការគិត គ្រប់ការធ្វើសកម្មភាពរបស់ខ្ញុំ។ និយាយទៅ ខ្ញុំក្មេងជាងគេច្រើន អ៊ីចឹងទោះបីគេមើលទៅមិនចាស់ជាងខ្ញុំប៉ុន្មានមែន តែប្រហែលជាគេអាចឃើញដល់ជម្រៅចិត្តថ្លើមខ្ញុំជាងខ្ញុំ ដែលមិនងាយដឹងពីអ្វីគេកំពុងលាក់ក្នុងស្នាមញញឹមនោះ។

ខ្ញុំរត់រ៉េវទៅបន្ទប់ទឹក កុំថាឡើយញញឹមតបគេ សូម្បីតែសម្លឹងគេទៀតក៏ធ្វើមិនបាន។

នៅក្នុងកញ្ចក់ពីមុខខ្ញុំ ខ្ញុំមើលទៅជាមនុស្សមិនចេះតុបតែងខ្លួន គិតថាខ្លួនឯងមិនស្រស់បស់ បានជាខ្ញុំមើលទៅចាស់សឹងតែស្មើគេទៅហើយ។ គេគិតម៉េច បានមកញញឹមដាក់ខ្ញុំហើយសម្លឹងខ្ញុំរបៀបហ្នឹង?

សម្រាប់ខ្ញុំ អារម្មណ៍បែបហ្នឹង គឺអារម្មណ៍ដែលមានគេមកក្នុងជីវិត សូម្បីតែគិតម្នាក់ឯង លបលួចប៉ងតែម្ខាង ក៏ដូចជាមានរសជាតិប្លែកៗ អ្វីៗគ្រប់យ៉ាងទៅជាពណ៌ ទៅជាសំឡេងខ្សឹបអាថ៌កំបាំង ទៅជាកម្លាំងចិត្តបណ្ដាលឱ្យខ្ញុំញញឹមវិញបានពេលនៅម្នាក់ឯង?

អារម្មណ៍ដែលមិនឯកោ អារម្មណ៍ថាអ្វីមួយល្អកំពុងកើតមានក្បែរៗខ្ញុំ និងអារម្មណ៍ថាកក់ក្ដៅទាំងមិនចាំបាច់ដណ្ដប់ ជាអារម្មណ៍ចាប់ពីកើតមកទល់ពេលនេះទើបតែមាន។

ខ្ញុំឱនលុបលាងមុខ បំបាត់ភាពក្ដៅស្លឹក និងបង្អាក់ស្នូរដង្ហើមដែលក្ដៅងំនឹកឃើញតែស្នាមញញឹមរបស់គេសិចស៊ីរោលរាល។

ថ្ងៃនោះក៏គិតថា សុំលុយពីម៉ាក់ទៅកាត់សក់ចង់បានម៉ូតថ្មីបន្តិច ហើយគិតថាចង់ដូរពណ៌សក់ទៀត ប៉ុន្តែដឹងមុនហើយ ថាម៉ាក់មុខតែមិនព្រម។

និយាយបន្តិចអំពីប៉ាម៉ាក់ខ្ញុំ!

ជាងមួយឆ្នាំមកហើយ ខ្ញុំកត់សម្គាល់ឃើញ ពីការផ្លាស់ប្តូរក្នុងគ្រួសារ ដែលធ្វើឱ្យខ្ញុំញញឹមលែងរួច។ របៀបដែលប៉ានិងម៉ាក់ មានអាកប្បកិរិយាសោះកក្រោះចំពោះគ្នាទៅវិញទៅមក ដំបូងៗបានធ្វើឱ្យខ្ញុំលួចនឹកគិតឆ្ងល់ថា មានអ្វីកើតឡើងលើពីរនាក់គាត់ លុះដល់ក្រោយៗមកសកម្មភាព«សង្គ្រាមត្រជាក់» មិនសូវមើលមុខគ្នា និងមិននិយាយរកគ្នាល្អួកល្អឺនទៀត។ ការដើរលេងរបស់យើង លែងមានបីនាក់ទៀតហើយ ម្តងប៉ានាំខ្ញុំដើរMall ហើយយកលេសថាម៉ាក់«រវល់» ម្តងម៉ាក់នាំខ្ញុំShopping ប្រើពាក្យ«ប៉ាហត់ចង់សម្រាក» យូរៗទៅពាក្យចចាមអារ៉ាមរបស់ញាតិដែលតែងខ្សឹបសួរថា ប៉ាម៉ាក់ឯងឮថា«លែងលះ» បានក្លាយជាថ្នាំបំពុលបង្វែរចរិតធម្មជាតិរបស់ខ្ញុំ។

ពីរួសរាយក្លាយជាស្ងប់ស្ងាត់ ពីញញឹមពព្រាយក្លាយជាក្រញូវៗ។

ធម្មតាខ្ញុំជាក្មេងសម័យទំនើប ខ្ញុំចូលចិត្តអានរឿងច្រើនណាស់ រឿងជីវិតខ្ញុំយល់ខ្លះដែរ តែការជ្រើសរើសបែកផ្លូវគ្នា ដោយមិនប្រាប់ខ្ញុំជាកូនបានន័យថា ខ្ញុំនេះជាមនុស្សមិនសំខាន់ម្នាក់។

ទម្លាប់កាលពីមុនមានឪពុកម្តាយដែលនៅសងខាងខ្ញុំជានិច្ច។ កាលពីខ្ញុំនៅតូចរហូតដល់ពេលដែលពួកគាត់ចាប់ផ្តើមឈ្លោះគ្នាញឹកញាប់ជាងធម្មតា ឈានដល់លែងនិយាយគ្នា តែការខ្វែងគំនិតគ្នាកើតឡើងកាន់តែធ្ងន់ខ្លាំងឡើងៗ ហើយចុងក្រោយ គាត់គេងដាច់ពីគ្នាដោយបែកបន្ទប់។ ម្តងម៉ាក់មកគេងនឹងខ្ញុំ ម្តងប៉ា។ មានពេលខ្លះខ្ញុំឃើញម៉ាក់ខ្ញុំ នៅលង់លក់លើសាឡុងដល់យប់ជ្រៅ គាត់ថាគាត់ជក់រឿងភាគ។

ការស្រឡាញ់ ប្រៀបដូចជាសារធាតុគីមីមួយ មើលមិនឃើញ គ្មានក្លិននិងប៉ះមិនកើត ពិបាកយល់ តែជះឥទ្ធិពលយូរអង្វែង ព្រោះមានអំណាចមន្តដ៏ខ្លាំងមួយពិបាកពិពណ៌នា គ្រប់គ្នាថាវាគួរឱ្យខ្លាច លំបាកឆ្លងកាត់ លំបាកថែរក្សាផង ចុះហេតុអ្វីមនុស្សម្នាតែងចង់បានវាមកម្ល៉េះ?

ខ្ញុំចុចអានប៉ះពាក្យទាំងប៉ុន្មាននេះ ហើយខ្ញុំចុចរំលងមកអានមួយឃ្លាទៀតរបស់មហាត្មះគន្ធី–Mahatma Gandhi ពាក្យថា "Where there is love there is life." បានន័យថា ពេលមានចិត្តស្រឡាញ់ ជីវិតនឹងកម្រើករស់រវើក។

«លួចអានរឿងស្នេហាទៀត?!»

សំឡេងចម្លែកនេះ មិនដែលស្គាល់ទេ លាន់មកពីចំហៀង គឺក្បែរៗកៀកៗព្រហើនៗ។ ខ្ញុំកំពុងតែអង្គុយអានជាមួយ Laptop ក្នុងបណ្ណាល័យសាលា ស្រាប់តែម្ចាស់សំឡេងនេះ ទម្លាក់សៀវភៅក្អុកៗក្បែរៗខ្ញុំក្រោយពីនិយាយឌឺៗរួច។

ខ្ញុំងាកទៅឃើញមុខអ្នកទម្លាក់សៀវភៅព្រហើននេះ ទាំងបេះដូងសឹងថាហោះហើរចេញពីទ្រូងបាត់ទៅភ្លាមៗ។

ដូចជាស្រមោលអន្ទោលតាមប្រាណពេកហើយ!

លងខ្ញុំក្នុងអារម្មណ៍ គ្រប់ពេលវេលា តាំងពីបានឃើញគ្នាដំបូង ឥឡូវមកទាញកៅអីអង្គុយក្បែរ ទម្លាក់របស់របរក្តុងក្តាំង ចង់ប្រាប់ថាជិតដិតនឹងខ្ញុំ? ស្គាល់គ្នាពីពេលណាមក?

ក៏ដូចជាចង់ផ្ដើនខ្ញុំវិញថា គេបានដឹងទាំងអស់រឿងរបស់ខ្ញុំ បានជាក្រោយលើកជើងមកគងអង្គុយក្បែរៗហើយ ក៏បោះសំណួរមកចំៗ មិនរង់ចាំឱ្យវិនាទីរំលងទាន់។

«ឈ្មោះភក្ត្រាមែនអត់?»

សំឡេងរបស់គេដែលសួរខ្ញុំឮៗ ដូចជាមនុស្សដែលមានចរិតមកពីបរទេស ចូលចិត្តនិយាយត្រង់ទៅត្រង់មក ហើយមិនខ្វល់ថា អ្នកណាគិតអ្វី ឬទុកគ្រប់គ្នាក្នុងបន្ទប់នេះជាទេសភាព គ្មានវិញ្ញាណ។

ខ្ញុំមិនដឹងថា ខ្លួនឯងភាំង ឬស្លឹឱ្យប្រាកដទេ!

ម៉េចគ្រប់គ្រងខ្លួនឯងមិនបាន? សម្លឹងមុខប្រុសស្អាតឡើងចំហមាត់ហើយដឹង បានជាឃើញស្នាមញញឹមគេថ្ពក់ជាប់មកជានិច្ច?

ដកភ្នែកចេញជេសម៍!!!

ខ្ញុំចង់ណាស់ តែបបូរមាត់គេ ដូចថ្ពក់ខាបអស់កម្លាំងកំហែង រារាំងសកម្មភាពខ្ញុំមិនឱ្យធ្វើចលនាបាន។

គេគ្រប់គ្នាដែលមកទីនេះ ធម្មតាមកអានសៀវភៅ ឬក្រុមខ្លះ គេពិភាក្សាការងារជាក្រុមដែលគ្រូចាត់តាំង។ ឥឡូវសឹងទាំងអស់គ្នា កំពុងងាកមកមើលមុខបងTN ហើយក៏មើលមុខខ្ញុំ។ យើងក្លាយជាចំណុចស៊ីប ដែលកំពុងធ្វើការហ៊ុមព័ទ្ធដោយកែវភ្នែករាប់សិប។

ខ្ញុំងាកសម្លឹងអ្នកទាំងនោះដោយមិនមាត់មិនក ធ្វើឱ្យពួកគេឈ្ងោករកការងារគេវិញធម្មតាដូចគ្មានអីកើតឡើង។ អ្វីដែលនៅសល់ គឺទេវបុត្រក្នុងសុបិនដែលបង្អួតស្នូរដង្ហើមខាងឆ្វេងដៃខ្ញុំ។

ហេតុអីចិត្តមានគេយ៉ាងជ្រៅងប់ បែរជាពេលមកតទល់ ធ្វើតោះតើយដាក់គាត់អ៊ុចឹង?

ខ្ញុំក៏មិនយល់! ចំពោះខ្ញុំ មិនដែលទម្លាប់ញញឹមផង កុំថាឡើយមានអ្នកណាមកអង្គុយជាមួយម្នាក់នៅទីនេះ។ គ្រប់គ្នាទម្លាប់ឃើញខ្ញុំឯកោស្រាប់ហើយ។

ច្រើនឆ្នាំមកនេះ ខ្ញុំមានបញ្ហាជាច្រើននៅក្នុងផ្ទះ។ ប៉ាម៉ាក់របស់ខ្ញុំម្ដងៗឈ្លោះផង លេងសម្ដីផង សឹងតែពិបាករស់ជាមួយគ្នានៅក្រោមដំបូលតែមួយ។ ការលែងលះ របស់ពួកគាត់តែងតែជាសុបិនអាក្រក់គម្រាមកំហែងខ្ញុំ។

ខ្ញុំមិនចង់និយាយពីរឿងក្នុងផ្ទះទៀតទេ គ្រាន់តែចង់ប្រាប់ថា ពេលនេះគឺសប្បាយចិត្តខ្លាំងឃើញគេ តែពិបាកចិត្តខ្លាំងដែរដែលគេមកកៀកម្ល៉េះ?

ច្រមុះខ្ញុំចាប់ផ្ដើមសម្គាល់បាននូវក្លិនទឹកអប់របស់គេ ដែលជាប់លើខោអាវគេបានប្រគល់មកឱ្យខ្ញីប៉ុន្មានថ្ងៃមុន។

«ខ្ញុំមិនទាន់បានយកមកសងបងផង ខោអាវបង!»

«សងធ្វើអី! ខោអាវប៉ុណ្ណឹងទើសផ្ទះណាស់?!»

ហើយអារម្មណ៍សម្ងាត់មួយបានពន្យុះខ្ញុំថា បុរសម្នាក់នេះដូចជាមើលទៅដូចជាព្រានៗ? នៅក្នុងបន្ទប់ខោអាវអត់និយាយសោះ លេងតែភ្នែក ពេលនេះនិយាយដូចមនុស្សផ្សេងម្នាក់?

ស្នាមញញឹម ក្លិនសិចស៊ីៗ មកក្បែរសឹងចែកដង្ហើមគ្នាប្រើបានទៅហើយ។

អារម្មណ៍មើលទៅដូចជាខ្លួនឯង ជាតួស្រីស្អាតទៅក្នុងកុនកូរ៉េ បានកើតឡើងពេលនេះម៉ោងនេះ ទាំងខ្ញុំជាមនុស្សប្រុសសុទ្ធសាធ មិនថាកម្ពស់កំពស ស្បែក សម្បុរ សក់ សំឡេង ម្រាមដៃជើងលើកលែងតែ បេះដូងខ្ញុំ។

ខ្ញុំជាប្រុសស្រឡាញ់ប្រុសមែនឬមិនមែន ខ្ញុំអត់ដែលមានពេលពិសោធន៍ទេ តែវាអត់បញ្ហាអីទាំងអស់សំខាន់បេះដូងរបស់ខ្ញុំនៅពេលនេះ គឺខ្ញុំពិតជាចង់មើលបបូរមាត់របស់គាត់ដែលនៅក្បែរៗខ្ញុំនេះម្ដងទៀត! ខ្លាចភ្លេច! ហើយនិងស្នូរដកដង្ហើមរបស់គាត់ ដូចជាចង់ត្របាក់យកស្នូរក្ដុកក្ដាក់ពុះកញ្ជ្រោលនៅក្នុងជម្រៅឱរា។

«ខ្ញុំឈ្មោះទេពណារ៉ា»

«ខ្ញុំស្គាល់បងឯងច្បាស់» អ៊្ហូយ! ឆ្លើយនឹងគេធ្វើអី? ហើយឆ្លើយអ៊ីចឹងបានទៀត?

តែជ្រុលទៅហើយ ខ្ញុំធុញខ្លួនឯងដែលពូកែខាងភ្លាត់មាត់។ ពេលម៉ាក់សួរ មិននិយាយមិនតបបានរាប់ថ្ងៃ ចំណែកប្រុសស្អាតវិញ នៅមិននៅ ទៅឆ្លើយតបអស់ពីបេះដូង ធ្វើសំឡេងខ្សាវៗដូចឯងហ្នឹងជាតួកំពុងរងគ្រោះក្នុងសមុទ្រស្នេហ៍ រង់ចាំទេវបុត្រសេះសហោះមកស្រោចស្រង់។

គេខ្សឹបម្តងដោយប្រើសឹងមិនដល់ដប់ភាគរយនៃសំឡេងក្រអួនក្រអៅមុននេះរបស់គេ៖

«ចង់ញ៉ាំអីគេអត់?! ខ្ញុំហៅឱ្យ!»

«អត់ទេ! ខ្ញុំអត់ញ៉ាំកាហ្វេទេ!»

«មានហ៊្នាថាហៅកាហ្វេ?!»

គេញញឹមដាក់កែវភ្នែកក្រឡាប់ចាក់របស់ខ្ញុំ។ ខ្ញុំឆ្លើយក្រឡាប់ផ្កាប់ផ្ងារព្រោះនៅមិននៅទៅច្រឡំស្មានតែគេចង់ហៅកាហ្វេមកឱ្យខ្ញុំ។

ដ្បិតតែកន្លែងនេះមានតូបកាហ្វេម៉ាស៊ីនតូចមួយ តែខ្ញុំមិនចេះកាហ្វេទេ។ នៅក្នុងបណ្ណាល័យរបស់យើងខ្ញុំជឿថា គេកំពុងតែមើលមកទៀតហើយព្រោះអ្នកណាៗក៏ស្គាល់បងTNដែរ។

ហួសចិត្តដែលខ្លួនឯងមានប្រតិកម្មលឿនហើយត្រូវគេជាន់កែងរហូត។

គេនេះមើលទៅចង់មកលលេងញែប៉ប្រែដាក់ខ្ញុំ ឬក៏គិតថាខ្ញុំចាញ់ប្រាប់ខ្លួន និយាយមិនឈ្នះរហូតនោះ?

ខ្ញុំក្តាប់មាត់តាំងចិត្តតបវិញខែងរ៉ែង៖

«ដូរសម្តីវិញបានតាស៎ ស្មានថាបងឯងមិនដែលនិយាយខុស? ខ្ញុំគ្រាន់តែចង់ថា ខ្ញុំអត់ទិញអីទេ!»

« Lit »

គេឆ្លើយខ្លី ខ្សោយហើយប្រ៊ើកន្ទុយភ្នែកដៀងមកខ្ញុំ មុនពេលបោយដៃហៅអ្នកលើកកាហ្វេ។

ចេះភាសាស្លែង គ្រាមភាសាទៀត? ខ្ញុំគិតម្នាក់ឯងដោយមុខក្រហម។ ពាក្យ Lit នេះធម្មតាជាភាសារបស់ជំទង់លោកខាងលិច ក្នុងន័យដូចAmazing ឬ Cool ឬមួយ Excitingដែរ។

ខ្ញុំប្តូរទៅធ្វើជាកំពុងអានមេរៀនវិញ ពេលគេនិយាយជាមួយអ្នកលក់។ គេងាកមកវិញ ហើយថាព្ញៗ៖

«ចូលចិត្តជិះកង់យូរនៅ?!»

ខ្ញុំងើបមុខជំនួសចម្លើយ។ អ្នករត់តុទើបតែបែរខ្នងដើរចេញមិនទាន់បានពីរជំហាន ស្រួលបួលផង គេនេះលេងភ្នែកដាក់ខ្ញុំលើគោកទៅហើយ។ មនុស្សមិនធ្លាប់មានស្នេហាដូចខ្ញុំ មិនមែនបានន័យថាខ្ញុំមិនស្គាល់ «ការចែចង់» ឯណា? ការសម្លឹងដូចកំពុងស្កេនយកប្រស្រីភ្នែកខ្ញុំបែបនេះ ចង់បញ្ចូល Virus មកក្នុងបេះដូងខ្ញុំប្រាកដណាស់។

«ភក្ត្រាចេះជិះកង់យូរនៅ?!»

«បងហៅខ្ញុំជេមស៍ក៏បាន!»

ខ្ញុំដកភ្នែកចេញយឺតៗហើយតបដោយសុភាពរាបសា។ សូរទូរសព្ទគេរោទ៍ គេងាកទៅចុចវាបិទហើយងាកមកវិញ។ ទោះគេមិននិយាយអ្វីទៀតនៅឡើយ តែតាមកន្ទុយភ្នែកខ្ញុំដឹងថា គេនៅញញឹម ហើយសម្លឹងមកជាប់។

មានអារម្មណ៍មិនជាស្រួលប៉ុន្មានទេ ដែលទើបនឹងដឹងថា គេនេះជាប្រភេទមនុស្សដែលញៀខ្ញុំត្រង់ៗមិនចាំស្អែក ប៉ុន្តែសំណួរធំ និងសំខាន់មួយគឺ «ហេតុអីជាខ្ញុំ?»។

«ស្អែកមានកម្មវិធីជិះកង់មួយ ចង់ចូលរួមដែរ?!»

គេសួរខ្ញុំស្រាលៗបន្ទាប់ពីខ្ញុំដកភ្នែកចេញលែងឱ្យស្កេន។ ខ្ញុំមិនមែនមិនចេះពង្រឹងទំនុកចិត្តចាប់យកស្នេហាគ្រាដំបូងជាមួយមនុស្សគួរជាទីចាប់អារម្មណ៍ម្នាក់ទេ តែបើអ្វីៗមកដល់លឿនពេក ដូចក្នុងកុនអ៊ីចឹង ខ្ញុំចេះតែមានអារម្មណ៍ថាអ្វីមួយខុសៗ មិនសូវស្រួលកំពុងតែកើតមានឡើង។

«ស្អែកខ្ញុំឆ្លងម៉ោង!» ខ្ញុំតបតិចៗទោះបីកុហកក៏ដោយតែខ្ញុំធ្វើដូចមែនទែន។ អ្ហឹយឡប់មែន យប់ឡើងនឹកគេចង់ឆ្កួត ស្រាប់តែឥឡូវនេះប្រកែកជាមួយការបបួលរបស់គេ។ ចរិតយ៉ាប់ សមណាស់ ទៅដេកវេទនាទៀតហើយ! ខ្ញុំបន្ទោសខ្លួនឯងទាំងសៅហ្មង។

«សក់ស្អាតម៉េះ?!»

គេដូរប្រធានបទបានភ្លាម ជាមួយនឹងការសរសើរមួយដែលជាភស្តុតាងច្បាស់ក្រឡែតនៃការចែចង់ផ្ទុះឡើង គួរឱ្យស្រលាញ់សឹងបេះដូងនេះធ្លាក់ទន់ភ្លាមបាន តែខ្ញុំខំធ្វើស្ងាត់ស្ងៀមដូចកាលខ្ញុំធ្វើមិនឮរាល់ពេលប៉ាម៉ាក់ខ្ញុំលេងសម្ដីលើតុបាយល្ងាចរបស់យើង។

«អរគុណ!» ខ្ញុំនិយាយតិចៗសឹងមិនចង់ឮ។

«និយាយខ្សោយម៉េះ?!»

គេថាឱ្យខ្ញុំហើយសើចឮៗ។ ខ្ញុំហួសចិត្តដំណាលនឹងការក្អិកក្អក់ដែរ ក៏ថាឱ្យវ៉ាវវិញក្នុងសំឡេងខ្សឹបដដែលៈ

«គេកំពុងធ្វើការជាក្រុមនៅជុំវិញយើង ដឹងរំខានគេអត់?!»

«ហ្ហ! កុំទៅខ្វល់! ពួកគេធ្វើដូចជាកំពុងរវល់តែ តាមពិតទៅក៏កំពុងចង់តាមដានយើងសឹងអីហ្នឹង!»

គេឆ្លើយមកក្បែរៗត្រចៀកខ្ញុំ ធ្វើឱ្យបេះដូងខ្ញុំលោតភឹប ខ្លាចតែអ្នកដទៃឮហើយខឹងយើងទេ។

ខ្ញុំរេភ្នែកសម្លឹងគ្រប់គ្នាម្ដងមួយៗ។

បងម្នាក់នេះ វិញបើកកុំព្យូទ័រគាត់ បង្ហាញថាមិនចេញទៅណាទាំងអស់ គឺអង្គុយដុះស្មឹមនៅហ្នឹង ធ្វើដូចស្គាល់គ្នាតាំងពីជាតិមុនមក?

«សុំស្គាល់Accountហ្វេសប៊ុកផង!»

ភ្នែកខ្ញុំសម្លឹងទៅម្រាមដៃធំៗរបស់គេលើ Keyboard។

ដោយសារតែម្រាមហ្នឹងឯង ដែលខ្ញុំវិលទៅផ្ទះវិញនឹកគេលើសដើម។ ហើយក៏ដោយសារតែ សារដំបូងរបស់គេបានជាជីវិតខ្ញុំត្រូវផ្លាស់ប្ដូរ!

«យប់ហើយ បានជ្រាម៉ាបន្តិចណាឬនៅ?» ខ្ញុំអត់យល់ន័យឃ្លានេះទេ ទោះអានចង់១០០ដងតែខ្ញុំនៅតែញញឹមទាំងមិនយល់ និងចិញ្ចឹមចិត្តចង់ជួបគេនៅព្រឹកបន្ទាប់។

«ហើយគ្មាននរណាម្នាក់ ធ្លាប់ធ្វើឱ្យខ្ញុំញញឹមពេញមួយយប់បានដូចសាររបស់បងទេ!»

ខ្ញុំសរសេរចោលលើហ្វេសប៊ុក អត់Mention អ្នកណាទាំងអស់ សង្ឃឹមម្ចាស់សារនឹងរើសដាក់ខ្លួន ហើយជួយប្រមូលទៅទុកលាក់កំបាំងឱ្យបានជ្រៅដល់ក្នុងគន្លុកគន្លាក់បេះដូងផងទៅចុះណ៎ា។

មនុស្សខ្ញុំនេះអាចថាមើលទៅឯកោ«ខុសគេ»របៀបខឹងផងស្នេហា បញ្ចេញអារម្មណ៍អីក៏រឹតតែខុសគេ។ តែខ្ញុំក៏មិនអីឯណាមើលចុះ! ដ្បិតអីការរស់ជាយុវវ័យសព្វថ្ងៃពិបាកណាស់ យើងប្រឈមទាំងឱកាសល្អ និងឱកាសអាក្រក់។ ត្រង់នេះខ្ញុំចង់និយាយពីហ្វេសប៊ុកនិងបណ្ដាញអ៊ីនធឺណេត។ មនុស្សវ័យស្របាលខ្ញុំជាច្រើនខ្លាចឯកោពេក ក៏ល្មោភចង់មានមិត្តភក្តិ ៥០០០នាក់លើហ្វេសប៊ុក មានអ្នកតាមដាន ៥០០០ នាក់ហើយចង់ទទួលបានយ៉ាងហោចណាស់ ១០០ Like ក្នុងមួយប្រកាសៗដែលសរសេរចេញ។ ហ៊ឹម អ្នកណាមិនចង់បានឱ្យមានគេយកចិត្តទុកដាក់? តែបើអ្នកនោះមិនស្គាល់យើងនៅក្រៅផង ឬមិនបានពាក់ព័ន្ធក្នុងជីវិតពិតផង មានន័យអី? យើងទទួលបានព័ត៌មានលឿនហើយបញ្ជូនវាកាន់តែលឿន។

Caption មិញនេះខ្ញុំមិនត្រូវការអ្នកណាយល់ អ្នកណាខ្វល់ទេ គឺត្រូវការតែគេម្នាក់ បានឃើញវាមករវល់នឹងវា យកវាខ្ចប់ទុកក្នុងបេះដូងក៏គ្រប់គ្រាន់។